**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**

លេខ : ១១៤ ផក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួលស្ថិតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- ពិនិត្យការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១**. ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដូចមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវ **ហង់ លីណា** | អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ | ប្រធាន |

| | | |
|---|---|---|
| ២. លោក **ហ៊ាង ភាណុរាល** | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | អនុប្រធាន |
| ៣. លោក **ឈួន សុធី** | ប្រធាននាយកដ្ឋាន វិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ |
| ៤. ឧត្តមសេនីយ៍ឯក **អ៊ុក គោសា** | នាយក នាយកដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| ៥. លោក **យ៉ា សារដេត** | ប្រធាននាយកដ្ឋាន ទីស្តីការគណៈរដ្ឋមន្រ្តី | សមាជិក |
| ៦. ឧត្តមសេនីយ៍ទោ **ប៉េច សុខត្ថិ** | ប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៧. លោក **យឹម សាលីន** | ប្រធាននាយកដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨. លោក **ញ៉ឹក វីរៈ** | ប្រធាននាយកដ្ឋាន ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩. លោក **គង់ ពុទ្ធារ៉ា** | ប្រធាននាយកដ្ឋាន ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. លោក **គង់ សុតារត្ន** | ប្រធាននាយកដ្ឋាន ក្រសួងទេសចរណ៍ | សមាជិក |
| ១១. លោកស្រី **យុន ច័ន្ទសោភា** | ប្រធាននាយកដ្ឋាន ក្រសួងយុត្តិធម៌ | សមាជិក |
| ១២. លោក **ម៉ា សុវណ្ណា** | ប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣. លោក **ច្រៀង ផល័ក្ខ** | ប្រធាននាយកដ្ឋាន ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤. លោក **ឆើម ឆាត** | ប្រធាននាយកដ្ឋាន ក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៥. លោក **ទឹម ដារ៉ា** | ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦. លោកស្រី **តែ ខួចលីម** | ប្រធាននាយកដ្ឋាន ក្រសួងកិច្ចការនារី | សមាជិក |
| ១៧. លោក **តាន់ សុខាន់** | ប្រធាននាយកដ្ឋាន ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៨. លោក **យិន សំរាយ** | ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |
| ១៩. លោក **ឌី ស៊ីម៉ាណែត** | ប្រធាននាយកដ្ឋាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២០. លោក **នេន ឯកនេតា** | អនុប្រធាននាយកដ្ឋានក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច | សមាជិក |
| ២១. លោក **សេង សុវណ្ណរ័ត្ននា** | អនុប្រធាននាយកដ្ឋាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២២. លោក **ស៊ីយ៉ុន សុតារិទ្ធ** | អនុប្រធាននាយកដ្ឋាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៣. លោក **ប៉ោង ពីទីន** | អនុប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៤. លោក **ប៉ាល់ ឧឌ្ឌិកា** | អនុប្រធាននាយកដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៥. លោកស្រី **មាស សុទ្ធាវី** | អនុប្រធាននាយកដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៦. លោក **មុត មីរ៉ាបូ** | អនុប្រធាននាយកដ្ឋាន ក្រសួងព័ត៌មាន | សមាជិក |
| ២៧. លោក **សែម វណ្ណៈ** | អនុប្រធាននាយកដ្ឋាន ក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៨. លោក **មឿង វិសុទ្ធ** | អនុប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២៩. លោក **ហ៊ល ធីរិត** | អនុប្រធាននាយកដ្ឋាន អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៣០. លោក **ហាក់ សុផល** | ប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣១. លោក **ខែត ពិសិដ្ឋ** | ប្រធានការិយាល័យ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៣២. លោក **គង់ សុខផល្លាគុណា** | ប្រធានការិយាល័យ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៣៣. លោក **ម៉ុន សារ៉េន** | អនុប្រធានការិយាល័យ ក្រសួងសុខាភិបាល | សមាជិក |
| ៣៤. លោក **តាន់ បញ្ញាពិសិដ្ឋ** | អនុប្រធានការិយាល័យ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

| | | |
|---|---|---|
| ៣៥. លោក **ទូច សុផាត** | អនុប្រធានផ្នែក ទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៣៦. លោក **នុយ មង្គលតុលា** | មន្ត្រី ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣៧. លោក **សុខ មករា** | មន្ត្រី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

**ប្រការ ២**. គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវប្រជុំការងារ យ៉ាងតិចរាល់បីខែម្តង។ សមាជិកគណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវកំណត់ចំនួនសមាជិកយ៉ាងតិចពាក់កណ្តាលនៃសមាជិកទាំងអស់សម្រាប់បើកអង្គប្រជុំ។ ក្នុងករណីសមាជិកចូលរួមមិនគ្រប់ កិច្ចប្រជុំលើកទី២ មិនគិតចំនួនសមាជិកចូលរួមឡើយ។

សេចក្តីសម្រេច របស់អង្គប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវអនុម័តដោយយកមតិភាគច្រើនរបស់សមាជិកចូលរួមទាំងអស់។

អគ្គនាយក ដែលជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិអនុម័តសម្រេចក្នុងករណីដែលមានមតិស្មើគ្នា។

រាល់ការប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវមានកំណត់ហេតុ។

**ប្រការ ៣**. គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានសិទ្ធិប្រើប្រាស់ត្រាវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ នៃវិទ្យាស្ថានជាតិស្ថិតិ ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ។

**ប្រការ ៤**. គណៈកម្មាធិការសម្របសម្រួលស្ថិតិ មានភារកិច្ចជួយវិទ្យាស្ថានជាតិស្ថិតិ ក្នុងការងារពាក់ព័ន្ធទៅនឹង៖

- ការកសាងគោលនយោបាយស្ថិតិ នីតិវិធី និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ
- ការធ្វើសមាហរណកម្មប្រព័ន្ធស្ថិតិជាតិមួយ តាមរយៈការសម្របសម្រួល និងសហប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាពលើសកម្មភាព និងការអភិវឌ្ឍស្ថិតិ រវាងអង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីទទួលខុសត្រូវ ក្នុងការផលិត និងការផ្សព្វផ្សាយស្ថិតិផ្លូវការ។
- ការធ្វើឱ្យប្រសើរឡើង និងការពង្រីកប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ ដែលផ្តល់សម្រាប់គោលដៅសាធារណៈ
- ការលើកអាទិភាព នៃកម្មវិធីការងារប្រចាំឆ្នាំ រយៈពេលមធ្យម និង រយៈពេលវែងដែលគួរត្រូវបានជ្រើសរើសទាក់ទងនឹងទិដ្ឋភាពសំខាន់ៗ នៃការផ្តល់ស្ថិតិផ្លូវការ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង។
- ការរៀបចំ និងធ្វើបច្ចុប្បន្នកម្ម ផែនការមេស្ថិតិ
- ការរៀបចំផែនការ ធ្វើជំរឿនប្រជាជន កសិកម្ម និងសេដ្ឋកិច្ច
- ការបង្កើតនូវបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌសរុប បញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ ព្រមទាំងថែរក្សាដោយប្រសិទ្ធភាព និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ
- កិច្ចព្រមព្រៀងសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល រវាងបណ្តាក្រសួង ស្ថាប័ន និងបណ្តាអង្គភាពរាជរដ្ឋាភិបាល អំពីការផ្លាស់ប្តូរទិន្នន័យ និងការផ្តល់ទាន់ពេលវេលានូវស្ថិតិផ្លូវការឱ្យបានទៀងទាត់ និងគួរជឿទុកចិត្តបាន

- ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ រយៈពេលកំណត់ ឬអចិន្ត្រៃយ៍ សម្រាប់ស្ថិតិណាមួយ ឬការងារស្ថិតិផ្សេងទៀត ដែលទាក់ទងនឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការ

- ការប្រកាសឱ្យប្រើ និងការអនុវត្តនូវចំណាត់ថ្នាក់ និងបទដ្ឋានស្ថិតិ ដែលទាក់ទងនឹងស្ថិតិផ្លូវការ

- ការលើកផែនការថវិកា និងធនធានមនុស្សសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និងអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលដៅសាធារណៈ។

**ប្រការ ៥.** នាយកខុទ្ទកាល័យ អគ្គនាយក នៃវិទ្យាស្ថានជាតិស្ថិតិ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដូចមានរាយនាមក្នុងប្រការ ១ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មានភារកិច្ចអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

ចម្លងជូន
- ខុទ្ទកាល័យក្រសួងផែនការ
- ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ